ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្ដាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០០៩/២៣-វ៉ាយ ធី ស៊ី ខបប៉ូរេសិន
កាលបរិច្ឆេទនៃសេចក្ដីបង្គាប់ ៖ ថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣

# សេចក្ដីបង្គាប់អាជ្ញាកណ្ដាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្ដីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្ដាល

អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី
អាជ្ញាកណ្ដាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្ដាលជ្រើសរើសឡើងដោយអាជ្ញាកណ្ដាលទាំងពីរខាងលើ ៖ ប៉ែន ប៊ុនឈា

## ភាគីនៃវិវាទ

### ១- ភាគីនិយោជក

ឈ្មោះ ៖ **ក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន**
អាសយដ្ឋាន ៖ ភូមិវល្លិ៍សរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ ៖ ០៧៧ ៧៧៧ ៨២៩ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោក គក មន្ត្រីអនុលោមច្បាប់
២- លោក សស មន្ត្រីរដ្ឋបាល

### ២- ភាគីកម្មករនិយោជិត

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ខបប៉ូរេសិន**
អាសយដ្ឋាន ៖ ភូមិវល្លិ៍សរ ឃុំវល្លិ៍សរ ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
ទូរស័ព្ទ ៖ ០៩៧ ៤៨៧៨ ០៦៥/០១០ ៦៣៩ ៨៨០ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក ទូស អនុប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
២- លោក ទក មន្ត្រីសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
៣- លោក អច ប្រធានសហជីពអភិវឌ្ឍន៍កម្មករ (មូលដ្ឋាន)
៤- លោកស្រី អស ប្រធានសហជីពសិទ្ធិកម្មករ (មូលដ្ឋាន)

## បញ្ហាក្នុងវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

១- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនរៀបចំស្ត្រីមានផ្ទៃពោះ និងស្ត្រីលូតកូន ស្ត្រីលូតកូន និងស្ត្រីដែលមកពីសម្រាលកូនវិញ នៅផ្នែកដេរ ឱ្យធ្វើការងារណាដែលស្រាលៗ។ ដោយឡែក ភាគីតំណាងនិយោជកបានបញ្ជាក់ថា ខាងក្រុមហ៊ុននឹងយកចំណុចនេះទៅពិភាក្សាជាមួយអ្នកបច្ចេកទេស និងថ្នាក់ដឹកនាំក្រុមហ៊ុនសិន ព្រោះមិនអាចផ្តល់ចម្លើយនៅថ្ងៃផ្សះផ្សានេះបានទេ។

២- កម្មករនិយោជិតស្នើសុំឱ្យក្រុមហ៊ុនបង់ប្រាក់ឱ្យកម្មករនិយោជិត នូវប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំយ៉ាងហោចណាស់គិតជាមធ្យមនៃប្រាក់បុព្វលាភ ប្រាក់វិភាជន៍ និងអត្ថប្រយោជន៍ផ្សេងៗ។ ដោយឡែក ភាគីនិយោជកបញ្ជាក់ថា ការឈប់សម្រាកប្រចាំឆ្នាំរបស់កម្មករនិយោជិត ក្រុមហ៊ុនអនុវត្តតាមច្បាប់ស្តីពីការងារ។

៣- ដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករនិយោជិត កុំអោយហេវហត់អស់កំលាំង ឬបណ្តាលឱ្យមានបញ្ហាវិលមុខ ដួលសន្លប់កើតឡើង សុំឱ្យក្រុមហ៊ុនផ្តល់លុយ ២០០០រៀល សម្រាប់ទិញអាហារប៉ូវសុខភាព ឬសុំអោយក្រុមហ៊ុនផ្តល់អាហារប៉ូវសុខភាពមួយពេលជូនកម្មករ ដើម្បីជួយធ្វើការបន្ថែមម៉ោងតាមការស្នើសុំរបស់ក្រុមហ៊ុន។ ដោយឡែក ភាគីនិយោជកបានបញ្ជាក់ថា ក្រុមហ៊ុនពុំមានលទ្ធភាពផ្តល់អាហារប៉ូវសុខភាពជូនកម្មករនិយោជិត ដែលធ្វើការបន្ថែមម៉ោងឡើយ ប៉ុន្តែក្រុមហ៊ុនបានផ្តល់ជូនកម្មករនិយោជិតរួចហើយ នូវប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០រៀល។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជា ឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំង សមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ១៨៥/២០ ក.ប/ប្រ.ក.រ.ក ចុះថ្ងៃទី២៩ ខែឧសភា ឆ្នាំ ២០២០ (អាណត្តិទី១៨)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែការផ្សះផ្សានោះភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ១៧៤/២៣ កប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃសុក្រ ១០កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១៣ និង ៣០ នាទី រសៀល។

ARBITRATION COUNCIL

បញ្ញានីតិវិធី ៖

នៅថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២៣ នាយកដ្ឋានវិវាទការងារ បានទទួលពាក្យបណ្តឹងរបស់តំណាងកម្មករ និយោជិតនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ស្តីពីកម្មករនិយោជិតទាមទារសុំឱ្យក្រុមហ៊ុនដោះស្រាយការទាមទារចំនួន ១០ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះរួចមក នាយកដ្ឋានវិវាទការងារ បានចាត់មន្ត្រីជំនាញធ្វើការដោះស្រាយវិវាទការងារនេះជាបន្តបន្ទាប់ និងបានធ្វើការផ្សះផ្សា នៅថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ ដោយទទួលបានលទ្ធផលសះជានឹងគ្នាចំនួន ៧ចំណុច។ ចំណុចមិនសះជាចំនួន ៣ចំណុច ដែលនៅសល់ ត្រូវបានបញ្ជូនមកក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ១៧៤ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើងនៅថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលបានអញ្ជើញភាគីនិយោជក និងភាគីកម្មករនិយោជិតមកសវនាការ និងផ្សះផ្សាលើករណីមិនសះជាចំនួន ៣ចំណុចនេះ នៅថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៣ វេលាម៉ោង ១ និង ៣០ នាទីរសៀល។ ភាគីទាំងពីរមានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញរបស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមស្វះរកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទមិនសះជាចំនួន ៣ចំណុចនេះ និងបានផ្សះផ្សាលើចំណុចវិវាទនេះបន្ថែមទៀត ដោយភាគីទាំងពីរបានព្រមព្រៀងចំនួន ២ចំណុច គឺចំណុចវិវាទទី១ និងចំណុចវិវាទទី២។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងពិចារណាលើចំណុចវិវាទដែលនៅសល់ចំនួន ១ចំណុច គឺចំណុចវិវាទទី៣។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច។

កាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលនៅថ្ងៃទី១៣ ខែមេសា ឆ្នាំ២០២៣។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទដែលនៅសល់ខាងលើនេះ ដោយផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

## ភស្តុតាង

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ (គ្មាន)

## ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលទទួលបាន

ក- ឯកសារបានទទួលពីភាគីនិយោជក ៖

១- លិខិតផ្ទេរសិទ្ធិលេខ ៣០-០៣/២០២៣ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២៣ របស់នាយកក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំផ្ទេរសិទ្ធិជូនលោក គ ក និង លោក ស ស ; មុខងារជាបុគ្គលិកប្រធានផ្នែកអនុឡោមច្បាប់ និងប្រធានរដ្ឋបាល ដែលមានសិទ្ធិ និងអំណាចពេញលេញក្នុងការដោះស្រាយបញ្ហាវិវាទការងារ ក្នុងនាមតំណាងឱ្យនាយកក្រុមហ៊ុន ព្រមទាំងមានសិទ្ធិសម្រេចរាល់កិច្ចព្រមព្រៀងផ្សេងៗផងដែរ ដើម្បីទំនាក់ទំនងជាមួយក្រុមប្រឹក្សាអាជ្ញាកណ្តាល ក្នុងករណីវិវាទការងាររួមនៅក្នុងសហគ្រាស យីហោ វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ក្នុងសំណុំរឿងលេខ ០០៩/២៣។

ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួម នៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣ នៅនាយកដ្ឋានវិវាទការងារ ។

៣- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មលេខ MOC-៧៧៦៥៣៨២៦ ពណ.ចបព ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៦។

៤- លក្ខន្តិកៈរបស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន បានតំកល់ទុកនៅនាយកដ្ឋាននីតិវិធី និងច្បាប់វិនិយោគ គ.វ.ក លេខ ១៤០៨/១៩ គ.វ.ក ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩។

៥- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន បានចុះទិដ្ឋាការលេខ ២៩៩ ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២០។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ (គ្មាន)**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ៖**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ១៧៤ ក.ប/អក/វក ចុះថ្ងៃព្រហស្បតិ៍ ២កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស ២៥៦៦ ត្រូវនឹងថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣។

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៣។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ០០៤/២៣ កប/អក/វក/កវក៤ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ របស់នាយកដ្ឋានវិវាទការងារ។

**ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ៖**

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ០៣៦ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ០៣៧ កប/អក/វក/លកអ. ថ្ងៃសុក្រ ៣កើត ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦ ត្រូវនឹងថ្ងៃទី២៤ ខែមីនា ឆ្នាំ២០២៣។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន មានសកម្មភាពចម្បង ផ្នែកកាត់ដេរសម្លៀកបំពាក់ និងមានជួលកម្មករនិយោជិតសរុបចំនួន ២៤៦១នាក់ មានស្ត្រី ១៧០៦ នាក់។ *(យោងតាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន វ៉ាយ ធី ស៊ី ឧបប៉ូរេសិន លេខ ១៧៤ ក.ប/អក/វក ចុះថ្ងៃទី២៣ ខែមីនា ឆ្នាំ២០២៣)*

- នាយកដ្ឋានវិវាទការងារបានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៤/២៣ កប/អក/វក/កវក៤ ចុះថ្ងៃទី១៦ ខែមីនា ឆ្នាំ២០២៣ ដែលមានកម្មករនិយោជិតចំនួន ៣ នាក់រួមមាន ៖ ១. អច ; ២. កស ; និង ៣. អច ។

ចំណុចវិវាទទី ៣ ៖ **ដើម្បីលើកទឹកចិត្តដល់បងប្អូនកម្មករនិយោជិត កុំឱ្យហេវហត់អស់កំលាំង ឬបណ្តាលឱ្យមានបញ្ហាវិលមុខ ដួលសន្លប់កើតឡើង សុំឱ្យក្រុមហ៊ុនផ្តល់លុយ ២០០០រៀល សម្រាប់ទិញអាហារប៉ូវសុខភាព ឬសុំឱ្យក្រុមហ៊ុនផ្តល់អាហារប៉ូវសុខភាពមួយពេលជូនកម្មករ ដើម្បីជួយធ្វើការបន្ថែមម៉ោងតាមការស្នើសុំរបស់ក្រុមហ៊ុន**

- ភាគីកម្មករនិយោជិតបានបញ្ជាក់ការទាមទារឱ្យនិយោជកផ្តល់ចំណីអាហារ ភេសជ្ជៈដែលមានជាតិស្កររាល់ពេលធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិត។
- ភាគីទាំងពីរទទួលស្គាល់ថា ៖
    - ផ្អែកតាមច្បាប់ នៅរាល់ពេលធ្វើការបន្ថែមម៉ោង កម្មករនិយោជិតត្រូវទទួលបានប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ២០០០រៀល ក្នុងមួយថ្ងៃ។ ដោយឡែក ចំពោះការអនុវត្តនៅក្នុងក្រុមហ៊ុន និយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០រៀល ក្នុងមួយថ្ងៃជូនកម្មករនិយោជិត។ ហើយនិយោជកផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ចំនួន ១០ដុល្លារអាមេរិកបន្ថែមទៀត ក្នុងមួយខែ ជូនកម្មករនិយោជិតដោយបូកបញ្ចូលជាមួយប្រាក់ឈ្នួលគោល។
    - ទោះបីជាកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ចំណីអាហារ ភេសជ្ជៈ ដែលមានជាតិស្ករនៅពេលធ្វើការបន្ថែមម៉ោងក៏ដោយ ក៏និយោជកនៅតែរក្សាអត្ថប្រយោជន៍ផ្សេងៗ ដូចជាប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០រៀល ក្នុងមួយថ្ងៃ ជូនកម្មករនិយោជិតដដែល។
    - មានតែកម្មករនិយោជិតនៅផ្នែកបង្ហើយការតែប៉ុណ្ណោះ ដែលបានធ្វើការបន្ថែមម៉ោងចំនួន ២ ម៉ោង ក្នុងមួយថ្ងៃ ចាប់ពីម៉ោង ៤រសៀល ដល់ម៉ោង ៦ល្ងាច។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា ៖
    - ដោយសារកម្មករនិយោជិតមានបញ្ហាហេវហត់អស់កម្លាំង រហូតមានការវិលមុខដួលសន្លប់នៅពេលធ្វើការបន្ថែមម៉ោង ទើបកម្មករនិយោជិតស្នើសុំឱ្យនិយោជកជួយផ្តល់នូវអាហារប៉ូវកម្លាំងដែលមានជាតិស្ករ ឬជាតិផ្អែម ដូចជា បង្អែម ឬកាហ្វេជាដើម ដល់កម្មករនិយោជិតតាមផ្នែកដែលនិយោជកស្នើឱ្យធ្វើការបន្ថែមម៉ោង។
    - ផ្អែកតាមសេចក្តីណែនាំរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ លេខ ០០៣ ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ នៅពេលធ្វើការបន្ថែមម៉ោង និយោជកត្រូវផ្តល់ឱ្យកម្មករនិយោជិតនូវចំណីអាហារ និងភេសជ្ជៈដែលមានជាតិផ្អែម ដើម្បីបំប៉នកម្មករនិយោជិត។
- ភាគីនិយោជកមិនអាចផ្តល់ជូនតាមការទាមទាររបស់ភាគីកម្មករនិយោជិតបានទេ ដោយមូលហេតុថា ៖
    - និយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០រៀល នៅពេលកម្មករនិយោជិតធ្វើការបន្ថែមម៉ោង ដែលការផ្តល់ជូននេះ គឺល្អប្រសើរជាងច្បាប់។
    - និយោជកពុំទាន់មានលទ្ធភាពនោះទេ ដោយសារស្ថានភាពសេដ្ឋកិច្ចមិនទាន់នឹងនរ ហើយថ្មីៗនេះលំហូរនៃការបញ្ជាទិញមិនទៀងទាត់ ជាហេតុនាំឱ្យក្រុមហ៊ុនព្យួរកិច្ចសន្យាការងារកម្មករនិយោជិតកាលពីថ្ងៃទី៩ ដល់ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០២៣ នេះផងដែរ។

**ហេតុផលនៃសេចក្តីសម្រេច ៖**

ចំណុចវិវាទទី៣ ៖ ភាគីកម្មករនិយោជិតទាមទារឱ្យនិយោជកផ្តល់ចំណីអាហារ ភេសជ្ជៈដែលមានជាតិស្ករ រាល់ពេលធ្វើការបន្ថែមម៉ោង ជូនកម្មករនិយោជិត

ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាថា តើនិយោជកមានកាតព្វកិច្ចផ្តល់ចំណីអាហារ ភេសជ្ជៈដែលមានជាតិស្ករ ជូនកម្មករនិយោជិត នៅពេលក្រុមហ៊ុនឱ្យកម្មករនិយោជិតធ្វើការបន្ថែមម៉ោងដែរ ឬទេ?

យោងសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា បានណែនាំថា ៖ *"...ដើម្បីជៀសវាងបាតុភូតមិនល្អទាំងនេះ និងដើម្បីរក្សាសុខភាព សុវត្ថិភាព របស់កម្មករនិយោជិតផង ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា សូមធ្វើការណែនាំដល់ម្ចាស់ និងនាយករោងចក្រ សហគ្រាស ពិសេសរោងចក្រកាត់ដេរសំលៀកបំពាក់ និងដេរស្បែកជើង ដូចខាងក្រោមនេះ ៖*

...

*៤- នៅគ្រប់ពេលមានធ្វើការបន្ថែមម៉ោង ក្រៅពីប្រាក់ឈ្នួលបន្ថែមម៉ោង រោងចក្រ សហគ្រាស ត្រូវមានការបំប៉នកម្មករនិយោជិតបន្ថែមទៀត ជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម ។ល។*

...

*ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា និងចាត់វិធានការតឹងរឹងបំផុតទៅតាមច្បាប់ចំពោះម្ចាស់ ឬនាយក រោងចក្រ សហគ្រាសណាដែលប្រព្រឹត្តល្មើសលើចំណុចដែលបានរៀបរាប់ខាងលើនៃសេចក្តីជូនដំណឹងនេះ ព្រមទាំងប្រកាសនានារបស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា កន្លងមក"។*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ០៣១/២២-អេ ផ្លាស់ អេ ស៊ូ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយថា ៖ *"ផ្អែកតាមខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ត្រង់ចំណុចទី៤ បានបញ្ជាក់យ៉ាងច្បាស់ ដែលនៅគ្រប់ពេលមានការធ្វើការបន្ថែមម៉ោង ក្រៅពីប្រាក់ឈ្នួលបន្ថែមម៉ោង រោងចក្រ សហគ្រាស ត្រូវមានការបំប៉នកម្មករនិយោជិតបន្ថែមទៀតជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម។ល។...យោងតាមសេចក្តីជូនដំណឹងនេះ និយោជកមានកាតព្វកិច្ចផ្តល់ការបំប៉នជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម ដល់កម្មករនិយោជិតនៅពេលធ្វើការបន្ថែមម៉ោង។ ហេតុនេះ នៅរៀងរាល់ពេលធ្វើការបន្ថែមម៉ោង កម្មករនិយោជិតត្រូវទទួលបានការបំប៉នជាចំណីអាហារដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម។" (សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ០៣៥/២២-យ៉ាកជីន (ខេមបូឌា) អ៊ីន ហេតុផលនៃចំណុចវិវាទទី៦ និងលេខ ០៤១/២២-ហ៊ីវ៉ាយហ្សិន អៅដរ (ខេមបូឌា) ហេតុផលនៃចំណុចវិវាទទី៧, លេខ ០០៦/២៣-លូស៊ីដា (ខេមបូឌា) អេនធើប្រាយ ហេតុផលនៃចំណុចវិវាទទី៥)*

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របតាមការបកស្រាយរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗខាងលើដែរ ពោលគឺនិយោជកត្រូវផ្តល់អាហារបំប៉នដែលមានជាតិស្ករ ឬភេសជ្ជៈដែលមានជាតិផ្អែម ជូនដល់កម្មករនិយោជិតដែលបានធ្វើការបន្ថែមម៉ោង ក្រៅពីប្រាក់ឈ្នួលបន្ថែមម៉ោង ដោយផ្អែកតាមខ្លឹមសារនៃសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ខាងលើ។

នៅក្នុងសំណុំរឿងនេះ ភាគីទាំងពីរទទួលស្គាល់ថា កម្មករនិយោជិតនៅផ្នែកបង្ហើយការបានធ្វើការបន្ថែមម៉ោងចំនួន ២ម៉ោង ក្នុងមួយថ្ងៃ ចាប់ពីម៉ោង ៤រសៀល រហូតដល់ម៉ោង ៦ល្ងាច ដោយនិយោជកបានផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោងចំនួន ៤០០០រៀល ក្នុងមួយថ្ងៃ និងផ្តល់ប្រាក់ថ្លៃបាយថ្ងៃត្រង់ចំនួន ១០ដុល្លារអាមេរិក ក្នុងមួយខែ ដោយបូកបញ្ចូលជាមួយប្រាក់ឈ្នួលគោល ជូនកម្មករនិយោជិត។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ការអនុវត្តរបស់និយោជក ក្នុងការផ្តល់ប្រាក់ថ្លៃបាយធ្វើការបន្ថែមម៉ោង និងប្រាក់ថ្លៃបាយថ្ងៃត្រង់ខាងលើ មានលក្ខណៈល្អប្រសើរជាងច្បាប់។

យ៉ាងណាមិញ យោងតាមសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. និងអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា និយោជកមានកាតព្វកិច្ចផ្តល់ចំណីអាហារបំប៉នដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម ជូនដល់កម្មករនិយោជិតនៅពេលធ្វើការបន្ថែមម៉ោង។ ដោយឡែក ភាគីនិយោជកមិនទាន់បានអនុវត្តកាតព្វកិច្ចផ្តល់ចំណីអាហារបំប៉នជូនកម្មករនិយោជិតតាមខ្លឹមសារនៃចំណុចទី៤ នៃសេចក្តីជូនដំណឹងនេះនៅឡើយ។ ហេតុនេះ និយោជកមានកាតព្វកិច្ចផ្តល់ចំណីអាហារបំប៉នដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែមជូនកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្តាលសម្រេច បង្គាប់ឱ្យនិយោជកផ្តល់ចំណីអាហារបំប៉នដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែមជូនកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ឱ្យស្របតាមសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

យោងតាមការបង្ហាញកស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សា-អាជ្ញាកណ្តាលសម្រេចចេញសេចក្តីបង្គាប់ ដូចតទៅ ៖

## សម្រេច និងបង្គាប់

**ចំណុចវិវាទទី៣ ៖**

- បង្គាប់ឱ្យនិយោជកផ្តល់ចំណីអាហារបំប៉នដែលមានជាតិស្ករ ដូចជាភេសជ្ជៈដែលមានជាតិផ្អែម ជូនកម្មករនិយោជិតដែលធ្វើការបន្ថែមម៉ោង ឱ្យស្របតាមសេចក្តីជូនដំណឹងលេខ ០០៣ សកបយ. ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០០៤ របស់ក្រសួងសង្គមកិច្ច ការងារ បណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា។

**ប្រភេទនៃសេចក្តីបង្គាប់ ៖ សេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្តីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្តីបង្គាប់ ចំនួន ០៨ថ្ងៃ បើសិនជាមិនមានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរ ទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ តាមរយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាលក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្តាល**
អាជ្ញាកណ្តាលជ្រើសរើសដោយភាគីនិយោជក ៖
ឈ្មោះ ៖ **អ៊ុក រី**
ហត្ថលេខា ៖ ------------------------------

អាជ្ញាកណ្តាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖---------------------------------

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **ម៉ែន ម៉ុនឈា**

ហត្ថលេខា ៖ ---------------------------------